01363647
Declassified to Public
12 June 2020

D337

លេខ៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 16 / 12 / 2016
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធាន៦៦ស្ទួន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេទ្ឋី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ នៅក្នុង*សំណើសុំសេចក្តីអធិប្បាយទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម*("សំណើសុំយោបល់") ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីគោលបំណងរបស់ខ្ញុំ ដែលនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុមួយចំនួន[1]។

៣. អោ អាន បានដាក់យោបល់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦[2] ហើយ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់យោបល់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦[3]។

៤. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ នៅក្នុង*សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ*("សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ")[4] ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោមដែលបានចោទនៅក្នុងដីកាសន្និដ្ឋានរបស់ ស.ព.អ ដែលជាបឋមបង្ហាញឱ្យឃើញថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន*៖

---

[1]សំណុំរឿង 00៤ ឯកសារ D307 *សំណើសុំសេចក្តីអធិប្បាយទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម* ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ៣, ៧។

[2]សំណុំរឿង 00៤ ឯកសារ D307/1 *សារណារបស់ អោ អាន ឆ្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្នើសុំផ្តល់យោបល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់មិនចាំបាច់ស៊ើបអង្កេតបន្ថែម* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦។

[3]សំណុំរឿង 00៤ ឯកសារ D307/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្នើសុំផ្តល់យោបល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់មិនចាំបាច់ស៊ើបអង្កេតបន្ថែម* ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦។

[4]សំណុំរឿង 00៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។ គួរកត់សម្គាល់ថា ការចោទប្រកាន់នានាគឺសំដៅលើអង្គហេតុមួយ។

ក) **អង្គហេតុ ក៖** ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣៖

- មន្ទីរសន្តិសុខទួលតាផ្លុង[5]
- មន្ទីរសន្តិសុខវត្តកណ្តាល[6]
- មន្ទីរសន្តិសុខចម្ការស្វាយចន្ទី[7]
- មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក[8]
- មន្ទីរសន្តិសុខវត្តស្រង៉ែ[9]

ខ) **អង្គហេតុ ខ៖** ការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា[10]

គ) **អង្គហេតុ គ៖** ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញដី[11]

ឃ) **អង្គហេតុ ឃ៖** ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស[12]។

៥. នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីគោលបំណងរបស់ខ្ញុំដែលចង់ដកអង្គហេតុ ក, ខ, គ និង ឃ ចេញពីកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* (“សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦*ស្ទួន*”)នៅពេលបិទកិច្ចស៊ើបសួរ[13]។

៦. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស.ព.អ បានដាក់សារណាដែលបង្ហាញថា គាត់មិនជំទាស់ជាមួយនឹងការដកចេញនូវអង្គហេតុ ក, ខ, គ និង ឃ ឡើយ ហើយបានឯកភាពថា អង្គហេតុដែលនៅសេសសល់គឺតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកា

[5] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥០-៥១។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥២។

[7] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣៤។

[8] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៣។

[9] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៩។

[10] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៥-៤៦។

[11] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣០-៣៣។ ដីកាសន្និដ្ឋានទី ២ កថាខណ្ឌ ១១។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១-២។

[12] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣០-៣១។

[13] សំណុំរឿង ០០៤ ឯកសារ D307/4 *សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន* ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម តាមភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តី[14]។ មិនមានភាគីណាផ្សេងទៀតបានដាក់សារណាឡើយ។

## II. ពិភាក្សា

៧. វិធាន ៦៦*ស្ទួន* (១) ចែងថា នៅពេលពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស អាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៨. នៅថ្ងៃនេះ យោងតាមវិធានផ្ទៃក្នុង ៦៦(១) ខ្ញុំជូនដំណឹងភាគីទាំងអស់ថា កិច្ចស៊ើបសួរប្រឆាំង អោ អាន បានបញ្ចប់។ ហេតុនេះ កិច្ចស៊ើបសួរនេះដល់ពេលដែលត្រូវចេញដីកាសម្រេច យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*។

៩. ខ្ញុំបានសម្រេចដកអង្គហេតុ ក, ខ, គ និង ឃ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* តាមសំអាងហេតុដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ និងសេចក្តីជូនដំណឹងយោងតាមវិធាន ៦៦*ស្ទួន*។

១០. ខ្ញុំយល់ឃើញថា អង្គហេតុដែលនៅសេសសល់គឺតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋាន តាមភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តីទាក់ទងនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម និងប្រភេទជនរងគ្រោះ។

១១. ដូចខ្ញុំធ្លាប់បានបញ្ជាក់ពីមុនរួចហើយ វិធានផ្ទៃក្នុង ៦៦ *ស្ទួន* (៥) បញ្ជាក់ច្បាស់ថា នៅពេលដែលដកអង្គហេតុចេញ ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញទាំងនេះនៅតែអាចប្រើប្រាស់ជាមូលដ្ឋានបានឱ្យតែពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។

[14] សំណុំរឿង ០០៤ ឯកសារ D307/4/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុលោមតាមវិធាន ៦៦ ស្ទួន(២)* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

១២. ការដកចេញនូវអង្គហេតុ ក, ខ, គ និង ឃ នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

១៣. **សម្រេច**ដកអង្គហេតុ ក, ខ, គ និង ឃ ចេញពីកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*។

ភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**